# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំគំរប់ ១៣

ភាគទី ២៣

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៤

គ.ស. ១៩៤១

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែពីរក្បាល

ឆ្នាំគំរប់ ១៣

ភាគទី ២៣

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយកទាំងពីរគណៈ
បានអនុញ្ញាតហើយ

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៤

គ.ស. ១៩៤១

# បញ្ជីរឿង


ទំព័រ

១ — អារ្យធម៌របស់ស្រុកខ្មែរ, ស្រង់យកអំពីរឿងមួយ ដែលលោកសឺដែសបាន រៀបរៀង (តមកពីលេខ ២៩ និងចប់) . . . . . . . . . . . . . ៣

២ — អំពីពុទ្ធសាសនាតាមយោបល់របស់បារាំងសែស . . . . . . . . . . ៥

៣ — អំពីប្រយោជន៍នៃកៅស៊ូ . . . . . . . . . . . . . . . . . ១១

៤ — ទេវទត្ត គឺអ្នកណា? . . . . . . . . . . . . . . . . . . ១៣

៥ — អំពីថ្នាំផ្លូងប្រភេទខ្លះ របស់ជីវកកោមារភច្ច (តមកនិងចប់) . . . . . . ១៨

៦ — ពង្សាវតារនៃក្រុងរោម, ស្រង់យកអំពីពោលបារិកផ្សេងៗក្នុងពង្សាវតារ លោក (តមក) . . . . . . . . . . . . . . . . . ២១

៧ — រឿងព្រេងខ្មែរ: "រឿងចោរលួចក្រដាស" . . . . . . . . . . . . . ២៥


## រូបក្រៅរឿង


សាមន្ត(ប្រទេសលាវ)-ស្រុកជៀងហ្លួង នេះរូបវត្តទំនើបថ្មី . . . . . . . . . ១

# TABLE DES MATIÈRES

Pages

1° Civilisation du Cambodge. Extrait d'un article rédigé par Monsieur Cœdès (suite du n° 21 de la revue et fin)....... 3

2° Le Bouddhisme vu par des Français .................... 5

3° Au sujet du caoutchouc............................... 11

4° Qui était DÉVADATTA ?.............................. 13

5° Quelques maladies contagieuses, par JIVAKA KOMARABHATYA (suite et fin)........................................ 18

6° Histoire de Rome. Extraits de divers documents de l'histoire universelle (suite)................................ 20

7° Conte populaire Cambodgien inédit : " Le voleur de papier "............................. 25

HORS - TEXTE

Samneua (Laos). Xieng-Luong, pagode moderne.......... 1

# ដំណឹងថ្មី

## អំពីព្រះរាជបណ្ណាល័យកម្ពុជា

ក្នុងខែមុននេះ យើងបានជូនដំណឹងដល់លោក-អ្នកហើយ ថាព្រះរាជបណ្ណាល័យបានបោះពុម្ពចេញផ្សាយអ្វីខ្លះ ដូចមានសេចក្ដីរាយការក្នុងទស្សនាវដ្ដីលេខ ៤២ ខែមុននេះរួចមកហើយ ។ ក្នុងខែនេះមានសៀវភៅថ្មីៗរបស់ព្រះរាជបណ្ណាល័យចេញផ្សាយថែមទៀត គឺ:

១ – ច្បាប់ក្រម ជាច្បាប់ចាស់មួយរបស់ខ្មែរប្រែកបដោយពាក្យកាព្យ ដែលអ្នកប្រាជ្ញជាតិខ្មែរបានតែងទុកមកយូរហើយ ។ ច្បាប់នេះកូនខ្មែរពីដើមជាប់តែទន្ទេញចាំមាត់រាល់គ្នា សៀវភៅនេះតំលៃ ១ ក្បាល ០រ.១០ ។

២ – ច្បាប់ត្រីនេតិ ជាច្បាប់ពាក្យកាព្យ ១ ទៀតជាស្នាដៃអ្នកប្រាជ្ញជាន់ដើមដែរ មានទុកទូន្មានល្អៗជាគ្រឿងប្រដាប់សតិបញ្ញារបស់កុមារកុមារីជាតិខ្មែរ តំលៃ ១ ក្បាល ០រ.១៥ ។

៣ – ច្បាប់រាជនីតិ ជាច្បាប់សម្រាប់ទូន្មានក្សត្រាក្សត្រី ទាំងនា-ហ្មឺនសព្វមុខមន្ត្រី ឲ្យចេះដឹងមុខក្រសួងរបស់ខ្លួន ដែលត្រូវធ្វើត្រូវប្រព្រឹត្តទាំងប៉ុន្មាន ជាសេចក្ដីពាក្យរាយងាយស្ដាប់ តំលៃ ១ ក្បាល ០រ.១៥ ។

៤ – មួយពាន់មួយយប់ ភាគ ៩ ជារឿងអារ៉ាប់ប្រែចេញមកពីភាសាបារាំងសែស រឿងនេះពីរោះអស្ចារ្យដូចម្ដេចៗ ខ្លះនោះសឹងលោកអ្នកបានជ្រាបស្រាប់ហើយ សៀវភៅនេះតំលៃ ១ ក្បាល ០រ.២៥ ។

ហេតុដូច្នេះ សូមអស់លោក-អ្នកអញ្ជើញទៅជាវមើលតាមត្រូវការ សឹងមានចំណាយជានិច្ចនៅព្រះរាជបណ្ណាល័យកម្ពុជា ទីកន្លែងលក់សៀវ-ភៅរបស់ព្រះរាជបណ្ណាល័យទូទៅ ។



សាមន្ធ (ប្រទេសលាវ) —ស្រុកជៀងហ្លួង នេះរូបវត្តទំនើបថ្មី ។

# អំពីអារ្យធម៌ខ្មែរ

ស្រង់យកអំពីសៀវភៅឥណ្ឌូស៊ិនរបស់លោកសឺដេស

កាលពី ព. ស. ១៨៥០ ស្ដេចលាវដំបូងដែលតាំងខ្លួនឯករាជ្យឡើងបាន ទ្រង់ព្រះនាម ហ្វាង៉ុម ហើយត្រូវជាកូនប្រសាស្ដេចស្រុកខ្មែរផង ក្សត្រអង្គនេះទ្រង់តាំងអាណាចក្រនៅហ្លួងព្រះបាង ហើយទ្រង់និមន្តពួកលោកសង្ឃខ្មែរទៅស្រុកនោះផង ៗ ក្នុង ព. ស. ១៩៥០ អាណាចក្រនេះធ្លាក់ទៅនៅក្រោមអំណាចមហាក្សត្រយួនម្ដង ហើយកាលពី ព. ស. ១៩៥០ (?) ប្រទេសនេះនៅក្នុងអំណាចស្ដេចគ្រងនគរថៃដែលនៅទិសខាងលិច ហើយតមកទៀតប្រទេសអស់នេះក៏ត្រូវពួកភូមាលុកលុយ (កាលពី ព. ស. ២០៩៩, ២១០៦, ២១១៤) ហើយថយក្រុងចុះមកក្រោមតាំងក្រុងថ្មីនៅវៀងចន្ទរួសព្វថ្ងៃនេះ ៗ ដល់ ព. ស. ២២៥០ អាណាចក្រនេះបែកចេញជា ២ កំណាត់ គឺហ្លួងព្រះបាងនិងវៀង-ចន្ទ ទើបមានកើតរឿងទាស់ទែងគ្នាដណ្ដើមអាណាចក្រលាវនេះក្នុងរវាងជាតិយួននិងសៀម តែសៀមមានជ័យជំនះក៏បានអាណាចក្រនេះទៅគ្រប់គ្រង រហូតដល់បារាំងសែសចូលមកកាន់កាប់គ្រប់គ្រង ៗ

តាមទំនងភូមិសាស្ត្រ អាណាចក្រហ្លួងព្រះបាងក៏មានទំនងដូចអា-ណាចក្រលាវឯទៀតៗដែរ តែងតែទទួលគ្រោះថ្នាក់អំពីឫទ្ធិអំណាចរបស់ប្រទេសជិតខាង គឺយួន, ខ្មែរ, សៀម, ភូមា ៗ បែបផែនវប្បធម៌

របស់យួនដែលចេញមកពីប្រទេសចិននោះក៏ចូលកាត់ប្រទេសនេះ តែមិនមានការប្រតិបត្តិតាមវប្បធម៌នេះនៅក្នុងប្រទេសលាវដល់សព្វថ្ងៃនេះឡើយ តែវប្បធម៌របស់ចិនយួន ផ្សាយទៅលើពួកថៃនៅដែនគុងកាំងខាងលើផងក៏យួន ជាទីមានទំនងជារបងកំងខណ្ឌដែនដីតាមភូមិសាស្ត្រដែលជាព្រំប្រទល់ដែនក្នុងចន្លោះប្រទេសទាំងពីរ ។

មួយវិញទៀត ប្រទេសខ្មែរ, សៀម និងភូមា ធ្លាប់វាយចំណែកប្រទេសលាវចែកគ្នាជាចំណែកៗអស់ទៅ ហើយពត់មួលកែប្រែអារ្យធម៌របស់លាវផង គឺខ្មែរនិងសៀមធ្លាប់មានអំណាចត្រួតលើក្រុងវៀងចន្ទន៍និងតាមបណ្ដោយទន្លេមេគុង ចំណែកខាងក្រុងហ្លួងព្រះបាងធ្លាក់ទៅនៅក្រោមអំណាចភូមាយ៉ាងស៊ប់សួន ៗ ប៉ុន្តែទុកជាយ៉ាងណាក៏ដោយ ប្រទេសនេះក៏ត្រូវឥណ្ឌាជ្រៀតជ្រែកចូលមកទាំងខាងផ្លូវសាសនា, ជំនឿ, ចំណេះវិជ្ជា រចនា និងអក្សរសាស្ត្ររបស់លាវ ហើយគេអាចទុកប្រទេសលាវនេះនៅចំពីមុខប្រទេសចិននិងយួនដែលកាន់តាមវប្បធម៌របស់ចិន តែអារ្យធម៌របស់ឥណ្ឌាក្នុងប្រទេសឥណ្ឌូស៊ីនគេទុកដូចជាទីពស្រួច (របស់លាវ) ។

**ចប់អារ្យធម៌របស់ខ្មែរតែប៉ុណ្ណេះ ។**

# វិធីពន្យល់ព្រះពុទ្ធសាសនាដល់ ប្រជាជនជាតិបារាំងសែស

ព្រះរាជបណ្ណាល័យកម្ពុជា ទើបនឹងទិញបានវចនានុក្រមភាសាបារាំងសែសខ្នាតធំៗ ចំនួន ៦ សៀវភៅ ក្នុង ១ សៀវភៅមាន ៨០០ ទំព័រ ហៅថា Dictionnaire Encyclopédique Quillet គឺជាវចនានុក្រមមួយ ដែលចុះផ្សាយវិជ្ជាការក្នុងលោកស្ទើរសព្វគ្រប់ របស់លោក គីយ៉េត៍ ដែលបានរៀបចំកិច្ចការដ៏ប្រសើរនេះ ទើបគេហៅវចនានុក្រមនេះថា វចនានុក្រមគីយ៉េត៍ ។

ប្រសិនបើយើងបើកមើលភាគទី ១ នឹងប្រទះឃើញពាក្យថា Bouddhisme (ព្រះពុទ្ធសាសនា) ដែលមានសេចក្ដីអធិប្បាយពន្យល់ដូច្នេះថា "ពុទ្ធនេះជាឈ្មោះរបស់អ្នកដែលបង្កើតសាសនានេះឡើង ជាលទ្ធិមួយ ដែលពោលអំពីគោលនៃបរមត្ថវិជ្ជា ហើយមានរបៀបជាសាសនាមួយ ជាដំណតមកអំពីលទ្ធិសាសនាព្រាហ្មណ៍ ដែលជាសាសនាចាស់របស់ឥណ្ឌៀ" ។

អ្នកបង្កើតពុទ្ធសាសនានេះបានមកចាប់កំណើតកើតឡើងក្នុងសតវត្សរ៍ទី ៦ មុនគ្រិស្តសករាជ មានឈ្មោះថា សិទ្ធត្ថ ក្នុងត្រកូលក្សត្រិសក្យៈ ដែលជាត្រកូលឧត្តមមួយតាមវណ្ណៈរបស់ព្រាហ្មណ៍ ។ ព្រះរាជបិតារបស់

ព្រះអង្គជាស្ដេចសោយរាជ្យនៅនគរកបិលពស្តុ ឯព្រះសិទ្ធត្ថៈរាជកុមារតែងមានព្រះទ័យមេត្តាករុណាដល់ជីវិតដ៏ថោកទាបលំបាកនៃពួកវណ្ណៈជាន់ទាប ទើបទ្រង់តាំងព្រះទ័យនឹងកែប្រែលទ្ធិសាសនាព្រាហ្មណ៍ជាថ្មីតាមសេចក្ដីប្រតិបត្តិអាក្រក់-ល្អរបស់មនុស្សទៅវិញ ទ្រង់ព្រះតំរិះដូច្នេះហើយទើបស្ដេចចេញចោលព្រះរាជវាំងរបស់ព្រះរាជបិតា ចូលទៅសម្ងំនៅក្នុងព្រៃ ទ្រង់បំពេញទុក្ករកិរិយា យ៉ាងតឹងរ៉ឹង ហើយស្ដេចចេញផ្សាយលទ្ធិថ្មីនេះ ក្នុងគ្រានោះគេហៅថា "លទ្ធិព្រះសក្យមុនី" មានតែមួយព្រះអង្គឯងទេដែលចេញចាកត្រកូលសក្យៈ ។

តមកមានព្រះនាមថ្មីមួយទៀតថា ពុទ្ធៈ (គឺអ្នកត្រាស់ដឹងរបស់ទាំងពួងឥតទើសទាល់) ហើយស្ដេចចេញទេសនាផ្សាយលទ្ធិថ្មីរបស់ព្រះអង្គក្នុងក្រុងធំៗ ។ អំណើះតមកព្រះអង្គបរិនិព្វាន ពួកសាវករបស់ព្រះអង្គក៏នាំគ្នាផ្សាយគំនិតបែបថ្មីនេះជាដំណាក់ៗគ្នាមកតទល់នឹងសាសនាព្រាហ្មណ៍មានផលចំរើនរុងរឿងក្នុងសតវត្សរ៍ទី ៥ នឹងទី ៦ នៃគ្រិស្តសករាជ (ព.ស. ៩៤៣-១០៤៣) ។ តមកពួកពុទ្ធសាសនិកជនត្រូវគេបៀតបៀនយ៉ាងខ្លាំងហើយបណ្ដេញឲ្យចេញពីប្រទេសឥណ្ឌា ពួកពុទ្ធសាសនិកជននាំគ្នាទៅតាំងផ្សាយពុទ្ធសាសនានៅសីឡង់ (លង្កា) នឹងតាមដែនដីនៅតាមមាត់សមុទ្រខាងត្បូង, នៅជួរភ្នំហិមាលយា ក្នុងស្រុកទីបេត៍ ស្រុកម៉ុង្កុល ហើយតទៅទៀតរហូតដល់ស្រុកចិននឹងស្រុកជប៉ុន ។

ពុទ្ធសាសនាសព្វថ្ងៃនេះ បើរាប់ចំនួនពុទ្ធបរិស័ទប្រហែលជា ៣០០ លាននាក់ដែលបែកចេញទៅជាច្រើននិកាយផ្សេងៗគ្នា ។ បរមត្ថវិជ្ជារបស់ពុទ្ធសាសនាជាផលដែលនៅខាងចុងនៃលទ្ធិសាសនាព្រាហ្មណ៍; លទ្ធិនេះមាននិយាយពីកំណត់បែបបទនៃវត្ថុធាតុនិងឥស្សរភាពនៃវត្ថុនិងសត្វដែលកើតឡើងដោយមានឧប្បត្តិហេតុផ្សេងៗពីគ្នា គឺថាក៏មានបែបសណ្ឋានទ្រង់ទ្រាយផ្សេងៗពីគ្នាជាអនេក ។ ឯព្រះពុទ្ធជាម្ចាស់ទ្រង់បញ្ចប់សេចក្តីថា របស់ទាំងអស់ជាអសារៈ ជាសម្បត្តិដែលតែងតែបែកធ្លាយទំលាយបង់ទៅទាំងអស់ ។ គំនិតនេះទុកជាផ្នែករបស់លទ្ធិនេះហើយមានបរមសច្ចៈដ៏ប្រសើរ ៤ យ៉ាងដែលមានសេចក្តីពន្យល់ក្នុងលទ្ធិហីនយាន ថាជាព្រះពុទ្ធដីកាដែរ គឺ សេចក្តីទុក្ខជារបស់ជាប់នៅនឹងភព (ទុក្ខសច្ចៈ) សេចក្តីទុក្ខកើតមកពីតណ្ហា (ទុក្ខសមុទយៈ) តែកពនឹងសេចក្តីទុក្ខអាចនឹងផុតរលត់ចេញពីគ្នាដោយសេចក្តីរលត់ទុក្ខជាន់ខ្ពស់ ឬព្រះនិព្វាន (ទុក្ខនិរោធៈ) ឯការប្រតិបត្តិឲ្យបានដល់នូវព្រះនិព្វានជាកន្លែងរំលត់ទុក្ខ ត្រូវតែកំចាត់បង់នូវតណ្ហារបស់ខ្លួនឲ្យអស់ទៅ (ទុក្ខនិរោធគាមិនីបដិបទា) ។

ពុទ្ធសាសនាព្រមតាមជំនឿសាសនាព្រាហ្មណ៍ ក្នុងការអន្ទោលទៅកាន់ភពនានា អស់នេះហើយជាកិច្ចលំបាកនឹងកែប្រែ ដែលមនុស្សយើងត្រូវតែស្វែងរកឧបាយចៀសវាង ដោយការកំចាត់បំផ្លាញតណ្ហានេះ ។

បរមត្ថវិជ្ជារបស់ពុទ្ធសាសនា តែងដឹកនាំសត្វលោកដែលកើតឡើងតាំងប៉ុន្មានឲ្យទៅកាន់ធម្មក្រិត្យាដ៏បរិសុទ្ធដ៏ឧត្តម ទើបទ្រង់ទេសនាឲ្យបំពេញការលះបង់ដោយខ្លួនឯង ពុំបីមានសេចក្តីស្តាយស្រណោះអាឡោះអាល័យ ត្រង់ណេះមានគោលខុសគ្នាឆ្ងាយនឹងគោលសីលធម៌ជារបស់សាសនាគ្រិស្ត ។

ព្រះពុទ្ធសាសនានេះ ជាគោលបរមត្ថវិជ្ជាមួយនឹងជាគោលសីលធម៌មួយ ដែលមិនមានពោលអាងដល់ព្រះជាម្ចាស់សួគ៌ ហើយទុកជាសាសនាមួយដែលបដិសេធអាត្មន ។ ក្នុងខណៈដែលលទ្ធិពុទ្ធៈនេះជាសាសនាមួយដូច្នេះ ធ្វើឲ្យមានជំនឿថា ជាសាសនាប្រកបដោយហេតុផលតាមសម័យនិយម ។ លទ្ធិពុទ្ធៈនេះដែលមានដំណើរដូចជាសាសនាមួយនោះដោយមានលក្ខណៈជាគ្រឿងកត់សំគាល់ ២ យ៉ាង គឺមានរបៀបរៀបចំតាំងគណៈសង្ឃឡើងម្យ៉ាង មានដួងចិត្តអត់ធ្មត់នៅជាឥស្សរៈដោយឡែក ( មិនបង្ខំសង្កត់សង្កិន ) ម្យ៉ាង ។ ឯដួងចិត្តមានអំណត់នេះមានលក្ខណៈជាបែបបរមត្ថវិជ្ជាសុទ្ធនឹងជាបែបសាសនាផង តែមិនមានព្រះជាម្ចាស់សួគ៌សម្រាប់ជាអ្នកហាមឃាត់ឬសម្រាប់បន់ស្រន់ឡើយ ។ ពួកពុទ្ធសាសនិកជនមិនមានគំនិតគិតបៀតបៀនដល់ពួកអ្នកកាន់សាសនាដទៃ ៗ ទេ ម្យ៉ាងទៀត លទ្ធិរបស់សាសនានេះប្រដៅឲ្យលះបង់ឲ្យមានចាគៈយ៉ាងងាយ ៗ គឺជាលទ្ធិមួយប្រកបដោយសេចក្តីនឿយណាយ ។ ពុទ្ធសាសនា

នេះផ្សាយចូលក្នុងប្រទេសឥណ្ឌូស៊ិន តាមពួកពុទ្ធសាសនិកជនជាអ្នកដំណើរដែលចេញពីស្រុកឥណ្ឌាទៅប្រទេសចិន ដើរកាត់ស្រុកតុងកឹង ។

ព្រះពុទ្ធសាសនាដែលព្រះសក្យមុនីទ្រង់ទេសនាប្រកាសផ្សាយ (មុនគ្រិស្តសករាជ ៥៦០-៤៨០ ឬពី ១-៨០ ឆ្នាំនៃពុទ្ធសករាជ) ដែលគេថ្វាយព្រះនាមថា ព្រះពុទ្ធ: "គឺអ្នកដែលភ្ញាក់រលឹកហើយ" (ក្នុងលោកមុនគេ) ។ ព្រះពុទ្ធជាម្ចាស់នេះទ្រង់ទេសនាប្រដៅឲ្យលះបង់របស់ទាំងក្រៅគប់ ៗ យ៉ាងដែលកើតមកពីធម្មជាតិមិនពិត ដែលធ្វើឲ្យយើងឃ្លាតឆ្ងាយពីសេចក្តីពិត គឺប្រាជ្ញាជាធម្មជាតិដ៏បរិសុទ្ធព្រះនិព្វាន ដែលមាននៅជុំវិញខ្លួនយើង ឲ្យចូលជ្រែកទៅក្នុងខ្លួនយើងវិញ ។ ឯការដែលបានជួបប្រទះនឹងព្រះនិព្វាននេះ មិនមែនដោយអំណាចព្រះព្រហ្ម (តាមជំនឿសាសនាព្រាហ្មណ៍នុះទេ) គោងតែពួកពុទ្ធសាសនិកជនការកែដោយខ្លួនឯង ទើបលះបង់សេចក្តីមិនពិតទៅជួបប្រទះនឹងសេចក្តីពិតគឺព្រះនិព្វាន ជាកន្លែងដែលវិញ្ញាណរួចផុតស្រឡះ ដល់នូវសេចក្តីរំលត់ទុក្ខ (គឺព្រះនិព្វាន) ។ ព្រោះហេតុនេះ ពួកពុទ្ធសាសនិកជនមិនត្រូវដកខ្លួនចេញពីសេចក្តីពិតនេះទេ គឺគិតប្រតិបត្តិទៅមុខដោយខ្លួនឯងទើបបានជាសេចក្តីប្រតិបត្តិត្រឹមត្រូវដ៏ឧត្តម វិញ្ញាណរបស់យើងមុននឹងរលត់ទៅ តែងអន្ទោលទៅកាន់កងកាយថ្មីមួយទៀត ដែលព្រះពុទ្ធជាម្ចាស់តែងអន្ទោលទៅកាន់ភពថ្មីទៀត ទ្រង់ចាប់កំណើតហើយផុតរលត់ទៅ

តាមដោយពិតនោះ ព្រះអង្គតែងអន្ទោលទៅកាន់កំណើតផ្សេងៗ ជាអនេកជាតិ ដើម្បីប្តេជ្ញាជាអ្នកប្រោសស្រង់សត្វលោក ទ្រង់បំពេញបារមីក្នុងភពនានា ត្រាតែចាស់ទុំបរិបូណ៌ ទើបមកកើតជាមនុស្សជាតិមួយសង្គ្រោះសត្វ រួចបានត្រាស់ជាព្រះពុទ្ធ ។ ប៉ុន្តែបើពោលតាមលទ្ធិមហាយាន នៅស្ថាននិព្វាននោះ មិនមែនត្រូវបានដល់មនុស្សម្នាក់ៗទេ តោងតែបានត្រាស់ជាព្រះពុទ្ធដោយការជំរះឲ្យស្អាតបរិសុទ្ធិ មកជាអនេកជាតិ ឯពួកអ្នកខ្សត់ត្រកាំងប៉ុន្មាន តោងតែព្រះពុទ្ធជាម្ចាស់ទ្រង់ដឹកនាំឲ្យបានសេចក្តីបរិសុទ្ធិ បញ្ចេញពីសេចក្តីអាក្រក់ផ្សេងៗ ក្នុងលោកនេះទៅកាន់លោកដែលមានព្រះពុទ្ធមួយព្រះអង្គទៀត មិនមែនរួចផុតស្រឡះពីតណ្ហាដោយខំទ្រាំខ្លួនឯងទេ តាមទំនងនេះហើយ ទើបធ្វើឲ្យមានជំនឿថានៅមានព្រះអរិយមេត្រៃយជាអ្នកជួយបន្ទោបង់ទូរសេចក្តីទុក្ខទាំងពួង ។

ចប់សេចក្តីពន្យល់ត្រង់ពាក្យថា ពុទ្ធសាសនា (Bouddhisme) ក្នុងវចនានុក្រមនោះតែប៉ុណ្ណោះ ។

# អំពីផលប្រយោជន៍កៅស៊ូ

នៅក្នុងខេត្តកំពង់ចាម កំពង់ធំ និងក្រចេះ មានចំការដើមហេវ៉ា យ៉ាងធំៗ ហេវ៉ានេះជាឈ្មោះដើមឈើដែលគេយកជ័រមកធ្វើជាកៅស៊ូ ។ ប៉ុន្តែកៅស៊ូនេះមានមនុស្សជាច្រើនដឹងថា គេយកកៅស៊ូនោះសម្រាប់ធ្វើជាកង់រថយន្តនិងកង់បីស៊ីក្លែតប៉ុណ្ណោះ ប៉ុន្តែតាមដោយពិតនោះ នៅមានវត្ថុដទៃទៀតជាច្រើនដែលគេបានធ្វើពីកៅស៊ូនោះ រឿងនេះនៅមានមនុស្សជាច្រើនមិនទាន់ដឹងសព្វគ្រប់ទេ ។ មានមន្ទីរជំនួញ ១ យ៉ាងធំក្នុងប្រទេសអាមេរិក គេយកកៅស៊ូនោះមកបោះធ្វើជាវត្ថុផ្សេងៗ បានច្រើនជាង ៣២.៦៤២ មុខ មានតំណាងនិងទំហំផ្សេងៗគ្នា ។ យើងមិនមានព្យាយាមនឹងរាប់ចំនួនរបស់អស់នោះដែលគេបានធ្វើពីកៅស៊ូឲ្យសព្វគ្រប់ក្នុងទីនេះទេ ប៉ុន្តែមានរបស់ខ្លះដែលគេតែងប្រើជាញឹកញាប់ដូចមានឈ្មោះខាងក្រោមនេះ :

មួកសម្រាប់ពាក់ងូតទឹក

ស្រោមដៃសម្រាប់គ្រូពេទ្យ

គ្រឿងលេងសម្រាប់កូនក្មេង ( ដូចរូបសត្វផ្សេងៗ )

ប័លឡុង

កម្រាលសម្រាប់បន្ទប់ងូតទឹក

កម្រាលសម្រាប់មន្ទីរពេទ្យ (ដើរជាន់លើកម្រាល មិនឮសូរសំឡេងទេ)

ធ្វើជាតួអក្សរពុម្ព (ទើបធ្វើកើតថ្មី)

ធ្វើខ្នើយបន្អែក

ធ្វើពូកសម្រាប់គ្រាលគ្រែ

ស្បែកជើង

ជបទឹកខ្មៅ

ធ្វើជាបំពង់ផ្សេងៗ

ធ្វើគ្រាប់គេទទិស

ធ្វើម៉ាស្គ (សម្រាប់ជួយឲ្យអ្នកជម្ងឺដកដង្ហើម ជាប្រដាប់សម្រាប់ពាក់នៅមុខ)

ធ្វើជាកាណូតតូចៗ

ធ្វើជាកម្រាលសម្រាប់គ្រាលនៅថ្នល់

ធ្វើជាឆាកល្ខោន ។

គេគិតធ្វើគ្រឿងផ្សេងៗពីកៅស៊ូជារបស់មានប្រយោជន៍ ក្នុងការចិញ្ចឹមជីវិតក្នុងសម័យសព្វថ្ងៃនេះ ទើបយើងឃើញថា ចំការកៅស៊ូនេះជារបស់សំខាន់ណាស់ ។

# ទេវទត្តគឺអ្នកណា?

មានអ្នកប្រាជ្ញម្នាក់ បានធ្វើសេចក្តីពិនិត្យអំពីរឿងនេះ ហើយធ្វើសេចក្តីកត់ហេតុមួយដោយសង្ខេបដូច្នេះថា:

ព្រះទេវទត្តជាពូជក្សត្រិយវង្ស រួមជាមួយនឹងព្រះពុទ្ធជាម្ចាស់ លុះពុទ្ធសាសនាកើតឡើងបាន ២០ ឆ្នាំ ទើបលោកចូលបួសជាភិក្ខុ ។ លោកជាប់ជាព្រះញាតិនឹងព្រះពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់មិនបានហាមឃាត់ទេវទត្តដែលមានចិត្តគំនិតមិនពិតប្រាកដមិនបរិបូណ៌ដូចជាព្រះអង្គក្នុងការថែរក្សាវិន័យបញ្ញត្តិនឹងលទ្ធិសាសនា ។ ប៉ុន្តែលោកមិនទាន់សំដែងឲ្យឃើញជាក់ស្តែងតាមគំនិតយោបល់ដែលប្លែកផ្សេងរបស់លោកទេ លុះ ១០ ឆ្នាំមុនព្រះពុទ្ធបរិនិព្វាន ទើបលោកក្រាបទូលសុំព្រះបរម-គ្រូ ដើម្បីកាន់ការត្រួតត្រាគណៈសង្ឃជំនួស តែរឿងនេះព្រះពុទ្ធជាម្ចាស់ទ្រង់ហាមឃាត់ ទើបលោកកបង្កើតរបៀបសាសនាថ្មីមួយឡើង ។ ឯការសំខាន់ៗដែលគេបានឃើញស្នាមលំអានជាង ១.០០០ ឆ្នាំមកនោះ គ្រាន់តែមានពោលចេញឈ្មោះក្នុងរឿងព៉របុកណានៃពុទ្ធសាសនា ។ គេមិនឃើញចេញឈ្មោះព្រះទេវទត្តក្នុងគម្ពីរសុត្តនិបាត ក្នុងគម្ពីរទីឃនិកាយក៏គ្មាន ។ ក្នុងបណ្ណាសកទាំង ៣ នៃសូត្រដទៃទៀត ក៏ជួនជាមានចេញឈ្មោះដល់ត្រង់ដែលនិយាយអំពីសាកច្ឆាពីរបៀបសីលធម៌ ប៉ុន្តែក្នុងគម្ពីរ

វិន័យបាលីជាន់ចាស់ ដែលហៅថា វិភង្គវិន័យ មានវគ្គមួយនិយាយពីរឿងរ៉ាវព្រះទេវទត្តនៅចុងក្រោយបង្អស់ ។ ការពិនិត្យតាមមើលរឿងនេះចែកចេញជា ៣ ផ្នែកគឺ:

១) តាមគម្ពីរវិន័យ

២) តាមរឿងរ៉ាវដែលរើសប្រមូលពីក្នុងគម្ពីរចាស់ ៗ

៣) តាមសេចក្តីកត់ហេតុក្រោយ ៗ មកទៀត ។

អំពីសេចក្តីប្រេះឆានៃគណៈសង្ឃ ដែលមានពោលទុកយ៉ាងពិស្តារក្នុងខន្ធក ១៨ នៃសុត្តវិភង្គនោះ មុនដំបូងនិយាយអំពីត្រកូលសក្យៈទាំង ៦ អង្គទ្រង់ចេញទ្រង់ព្រះផ្នួសជាភិក្ខុ ក្នុងចំនួននេះមានព្រះទេវទត្ត ១ អង្គផង ឯក្សត្រទាំង ៥ អង្គនោះ កាលទ្រង់ព្រះផ្នួសក្នុងព្រះសាសនាហើយបំពេញព្យាយាមទៅ ក៏បានសម្រេចគុណវិសេសក្នុងព្រះសាសនាទាំង ៥ អង្គ ឯព្រះទេវទត្តក៏បានសម្រេចឫទ្ធិមួយយ៉ាងដែរតែជាឈានលោកិយ ។

ក្នុងរឿងទី ១ និយាយថា ព្រះទេវទត្តរំពឹងពិចារណាស្វែងរកវិធីឱ្យបានផលប្រយោជន៍និងកិត្តិយស ទើបលោកទៅបំភ័យព្រះរាជកុមារអជាតសត្រូវ ជាមកុដរាជកុមារនៃមគធរដ្ឋ ដោយអំណាចឫទ្ធិរបស់លោក ហើយព្រះរាជកុមារទទួលរាប់អាន ៗ តែលោកនេះស្រវឹងនឹងលាភសក្ការៈដែលកើតឡើង ទើបរិះរកឧបាយចង់ធ្វើជាសាស្តាគ្រប់គ្រងគណៈសង្ឃ

ព្រះពុទ្ធជាម្ចាស់ទ្រង់ឲ្យព្រះមោគ្គល្លានត្ថេរចេញទៅក្រុងរាជគ្រឹះ ប្រាប់ឲ្យទេវទត្តដឹងខ្លួនជាមុន អំពីលាភសក្ការៈរបស់ទេវទត្តនាំឲ្យអន្តរាយដល់អាត្មា ៗ

ឯរឿងក៏ទី ២ និយាយអំពីទេវទត្តក្រាបទូលសុំព្រះពុទ្ធជាម្ចាស់ ឲ្យទ្រង់ប្រគល់គណៈសង្ឃមកខ្លួនត្រួតត្រា ព្រោះព្រះអង្គទ្រង់ជរាភាពណាស់ហើយ ៗ ព្រះពុទ្ធជាម្ចាស់ទ្រង់បដិសេធហើយទ្រង់ប្រកាសថា តាំងអំពីថ្ងៃនេះទៅ ទុកជាទេវទត្តត្រូវការអ្វីធ្វើអ្វីស្រេចតែទេវទត្តចុះ គ្មានការរួបរួមជាមួយនឹងគណៈសង្ឃរបស់ព្រះអង្គទេ ៗ តអំពីនោះមកព្រះទេវទត្តពោលពន្យល់មកុដរាជកុមារឲ្យសម្លាប់ស្តេច (បិតា) ទៅ រួចសុំឲ្យជួយលោកសម្លាប់ព្រះពុទ្ធជាម្ចាស់ទៀតផង ៗ

តមកទៀត ព្រះទេវទត្តបានបញ្ញត្តច្បាប់យ៉ាងតឹងរ៉ឹងអំពីលំនៅ (របស់ភិក្ខុ) អំពីការទទួលនិមន្ត, អំពីអាហារភោជន (ដែលមានត្រីសាច់) ព្រះពុទ្ធជាម្ចាស់ទ្រង់បដិសេធសេចក្ដីបញ្ញត្តិរបស់ទេវទត្តទាំងអស់ ទើបទេវទត្តប្រកាសថា ព្រះបរមសាស្ដានិងពួកសាវកប្រាថ្នាសេចក្ដីសុខស្រួលហ៊ឹហាណាស់ ហើយព្រះទេវទត្តបញ្ញត្តច្បាប់នេះឡើង តាមគំនិតយោបល់របស់ខ្លួន ហើយបបួលភិក្ខុក្មេងៗ មួយពួកចំនួន ៥០០ រូប ឲ្យប្រតិបត្តិតាម ៗ

ឯរឿងចុងបង្អស់មាននិយាយថា ព្រះទេវទត្តលោមលោមដោយពួកសា-វក កំពុងសំដែងធម៌ឲ្យពួកសាវកស្តាប់ ហើយបានអារាធនាព្រះសារីបុត្តនឹងព្រះមោគ្គល្លានឲ្យរួមនៅស្តាប់ធម៌ជាមួយនឹងគណៈសង្ឃនោះផង ។ សំដែងធម៌ដល់យប់ជ្រៅទៅ ក៏កាន់តែអស់កំឡាំងទៅ ទើបសុំឲ្យព្រះសារីបុត្តសំដែងធម៌ជំនួសខ្លួន ហើយសឹងលក់ទៅ ។ ព្រះសារីបុត្តបានចាត់ចែងធ្វើឲ្យភិក្ខុសង្ឃ ១ ភាគធំរបស់ព្រះទេវទត្តផ្លាស់ចិត្តគំនិត ត្រឡប់មកគាល់ព្រះពុទ្ធជាម្ចាស់វិញ ។

គម្ពីរមជ្ឈិមនិកាយ-សំយុត្តនិកាយ-អង្គុត្តរនិកាយ-ឧទាន-ឥតិវុត្តក ក៏មាននិយាយពីព្រះទេវទត្តដែរ នៅទីបំផុតគម្ពីរក្រោយៗមក ច្រើនមាននិយាយអំពីរឿងរ៉ាវព្រះទេវទត្តកាន់តែញឹកញាប់ឡើងជាប់នៅនឹងរឿងផ្សេងៗជាច្រើន ។

គម្ពីរមហាវគ្គនឹងគម្ពីរមហាវង្ស មានរឿងដំណាលប្លែកផ្សេងពីគ្នា អំពីពូជពង្សវង្សត្រកូលរបស់ព្រះទេវទត្ត ។ គម្ពីរមិលិន្ទបញ្ហាមានសេចក្តីដំណាលថាផែនដីស្រូបព្រះទេវទត្តចុះទៅ (នរក) ហើយក្នុងខណៈដែលនឹងស្លាប់នោះ ព្រះទេវទត្តរលឹកដល់ព្រះពុទ្ធម្ចាស់ជាទីពឹង ។ កាលពី ព.ស.៩០០ មានអ្នកធុតង្គជាតិចិនម្នាក់ឈ្មោះ ហ្វា-ហៀន បានកត់ត្រាការដែលផែនដីស្រូបព្រះទេវទត្តនោះថានៅមានរឿងនិយាយតៗ

គ្នាមកនៅឡើយក្នុងប្រទេសឥណ្ឌា ហើយក្នុងសម័យនោះសោតទៀតក៏នៅមានពួកសាវករបស់ព្រះទេវទត្តដែលគោរពនមស្ការព្រះពុទ្ធព្រះអង្គដែលកន្លងមកហើយ លើកលែងតែព្រះពុទ្ធគោតម ១ អង្គចេញ ។ ក្នុង ព.ស. ១.១០០ មានអ្នកធុតង្គជាតិចិនម្នាក់ទៀត ទៅសំណាក់នៅក្នុងប្រទេសឥណ្ឌាដែរ ឈ្មោះហៀនឆាង ក៏បានធ្វើសេចក្តីកត់ត្រាទុកដូចគ្នានេះដែរ ។

អំពីជម្ងឺក្មេងជំពូកទី ៤

(តពីលេខមុន)

# អាយុដែលគួរជោះអុត

ក្មេងដែលទើបកើត គួរជោះអុតតាំងអំពីអាយុនៅរវាង ១ ខែដល់ ៦ ខែ ៗ ការជោះអុតក្មេងតូច ៗ ដូច្នេះស្រួលច្រើនជាងក្មេងធំ ការជោះក្នុងរវាងអាយុនេះសំខាន់ណាស់ បើជោះម្តងមិនឡើងល្អតោងជោះថែមទៀត ៗ ដល់ពេលចូលរៀនក្នុងសាលាក្នុងរវាងអាយុ ៥–៧ ឆ្នាំ តោងជោះអុតម្តងទៀតជាគំរប់ពីរដង លុះដល់អាយុ ១៤ ដល់ ២០ ឆ្នាំ គួរជោះថែមទៀតជាគំរប់ ៣ ដង ៗ

# កន្លែងដែលជោះអុត

គួរជោះនៅដើមដៃខាងឆ្វេងខាងក្រៅ បើជាអ្នកធ្វើការដៃឆ្វេងទើងជោះដៃខាងស្តាំក៏បាន មិនគួរជោះអុតនៅជើងឬភ្លៅទេ ព្រោះអុតដុះឡើងនឹងចាប់ឈឺពិតច្រើនជាងជោះនៅដៃ ជាការលំបាកដល់ឥរិយាបថក្រោកដើរជាដើម ៗ កូនខ្ចីនោះមិនគួរជោះអុតនៅជើងទេ ព្រោះក្មេងបន្ទោបង់ឧច្ចារៈបស្សាវៈមកប្រឡាក់មុខដំបៅអុត ធ្វើឲ្យមុខដំបៅក្របានសះជា ៗ

# អាការរោគក្រោយជោះអុត

អ្នកដែលមិនធ្លាប់ជោះអុតសោះ បើជោះអុតៗនឹងដុះឡើងល្អ ហើយមានអាការសង្កើសង្កាញ់ស្រៀវស្រាញមិនឆ្ងាញ់បាយ មានគ្រុនបន្តិច

បន្ទប់ អុតដុះជាគ្រាប់ឡើងទុលក្រហមក្នុងថ្ងៃទី ៦ ហើយទឹកក្លាយទៅជាខ្ទុះក្នុងថ្ងៃទី ៩ តាមធម្មតា អុតនឹងស្រពោនទៅវិញក្នុងថ្ងៃទី ១២ ហើយជ្រុះក្រមរអុតប្រហែលក្នុងថ្ងៃទី ២១ ។

## វិធីរក្សាដំបៅអុត

តាមធម្មតា អុតតែងដុះឡើងហើយស្រះជាទៅឯង មិនបែកមុខដំបៅ តែត្រូវប្រយ័ត្នកុំឲ្យបែកធ្លាយ ព្រោះអាចនាំមេរោគឯទៀតចូលទៅធ្វើឲ្យមុខដំបៅអុតឈឺពេកក៏សឹងមាន ។ ការប្រយ័ត្នមិនឲ្យបែក គឺកុំប្រើថ្នាំអ្វីបិទឲ្យសោះ ឬគ្រាន់តែប្រើសំពត់ជ្រលក់ទឹកត្រជាក់ដែលដាំឆ្អិនបិទ មិនគួរប្រើថ្នាំពេយទេ ក្រែងគ្រាន់តែធ្វើឲ្យមុខដំបៅអុតនោះរីកធំពេកមិនល្អមើល ។

## ហាមប្រាម – មិនគួរជោះអុត

១ – អ្នកដែលកើតដំបៅពុះពងតាមកងកាយ ព្រោះធ្វើដំបៅនោះឲ្យកាន់តែកំរើកខ្លាំងឡើង ។

២ – អ្នកដែលមានរោគរើរៃ កងកាយស្គាំងស្គមជានិច្ច ។

៣ – អ្នកដែលកំពុងគ្រុន ។

មួយវិញទៀត មានអ្នកខ្លះយល់ថា ស្ត្រីមានគភ៌មិនគួរជោះអុត ប៉ុន្តែតាមពិត គួរតែជោះអុតមុនអ្នកដទៃ ព្រោះថាបើម្តាយកើតអុត កូនដែលនៅក្នុងផ្ទៃ កម្រនឹងបានរស់ណាស់ ។

# ការដោះអុតថែម

មានអ្នកខ្លះយល់ថា ដោះអុតម្តងហើយនឹងការពារអុតបានរហូតអស់ ១ ជីវិត នេះជាការចូលចិត្តខុសទាំងស្រុង ព្រោះបើពោលតាមវិជ្ជាការ ឃើញថា ការដោះអុតឡើងល្អម្តងហើយនោះ មានអំណាចការពារអុតព្រៃបានក្នុងរវាង ៥ ដល់ ៧ ឆ្នាំប៉ុណ្ណោះ គំពីនោះមកតោងដោះអុតថែមទៀត ការដោះជាតំរប់ពីរនេះការពារអុតព្រៃបានល្អណាស់ អ្នកដែលបានដោះអុតជាតំរប់ ៣ ដងហើយ កម្រនឹងកើតអុតព្រៃជាទីបំផុត ។

សួស្តីចូរមានដល់អ្នកមើលទស្សនាវដ្តីកម្ពុជសុរិយារបស់យើង

ខេមរាវៀ

# ពង្សាវតាររោម

(តមក)

## វគ្គទី ២

### អំពីសាសនា, ទំនៀមប្រពៃណីនិងរបៀបគ្រប់គ្រងស្រុក

ក-អំពីរបៀបសាសនា — ពួកអេស៊ិបនិងពួកក្រិកមានសេចក្ដីកប់អាននឹងគោរពព្រះផ្សេងៗជាចំនួនច្រើន ឯពួករ៉ូម៉ាំងមានព្រះដែលគេគោរពកប់អានច្រើនជាងជនទាំងពីរជាតិនោះទៅទៀត ។ ក្នុងវិហារផ្សេងៗ ច្រើនតែពាសពេញទៅដោយទេវរូប នៅវិហារមួយមានទេវរូបច្រើនជាង ៣០,០០០អង្គ មានអ្នកប្រាជ្ញពង្សាវតារក្នុងសម័យនោះពោលទុកថា កាលបើដើរចូលទៅក្នុងក្រុងរោម គង់នឹងមើលឃើញទេវរូបមានចំនួនច្រើនជាងមនុស្សទៅទៀត ។

សេចក្ដីប្រកាន់កប់អានរបស់ពួករ៉ូម៉ាំង បែងចេញជា ២ ប្រការ ដូចជាអេស៊ិបដែរ គឺកប់អានបុព្វបុរសនិងកប់អានព្រះផ្សេងៗ គ្រប់ៗដំបូលផ្ទះ មានទីបូជាបុព្វបុរសដែលគេបានអុជភ្លើងបូជាទុកទាំងយប់ទាំងថ្ងៃ ហើយមានទេវរូបផ្សេងៗ ដែលសន្មតថាជាអ្នកថែរក្សាផ្ទះសំបែង (ទំនងព្រះភូមិរបស់យើង) ។ ឯព្រះអង្គធំៗនោះ មានទំនងដូចជាព្រះរបស់ក្រិកដែរ គឺមានព្រះជាម្ចាស់សួគ៌ ព្រះនៃភ្លើង ព្រះនៃមង្គលការ, ព្រះនៃសិល្បវិជ្ជា, ព្រះនៃសង្គ្រាម, ព្រះនៃសមុទ្រ, ព្រះនៃលោហធាតុ, ព្រះនៃ

ដំណាំ ព្រៃជំនួញ ។ល។ ការគោរពកប់អានព្រះអស់នេះខុសគ្នានឹងលទ្ធិសាសនាឯណាឯទៀតៗ គឺថាមនុស្សដែលប្រកាន់កប់អាននឹងព្រះអគ្គអស់នោះ ប្រហែលនឹងអ្នកដែលធ្វើសន្យាជាមួយគ្នា មានទំនងដូចការបន់ស្រន់អារក្សអ្នកតាដែរ ពោលគឺបើខ្លួនត្រូវការបន់សុំអ្វី ក៏ទៅនិយាយបន់សុំព្រះតាមចំណង់របស់ខ្លួន កាលបើបានសម្រេចដូចបំណងហើយ ទើបធ្វើពិធីលាបំណន់ ។ ការធ្វើពិធីលាបំណន់នេះ ពួកលោកសង្ឃជាអ្នករៀបធ្វើ មុននឹងធ្វើគេរកឫក្សពារពេលាល្អ ជាពេលដែលព្រះមានព្រះទ័យស្រួលល្អ គេប្រើវិធីមើលផ្លូវសត្វហើរ, ស្តាប់សំឡេងសត្វយំ, មើលទិសដែលមានផ្លេកបន្ទោរ តែនៅមានវិធីដែលគេនិយមប្រើច្រើនបំផុត គឺបាចស្រូវឲ្យមាន់ចឹកស៊ី តែជាមាន់ដែលនៅនឹងផ្ទះអ្នកតា កាលបើឃើញមាន់នោះចឹកស៊ីស្រូវស្រួល ក៏ប្រកាន់ថាជាឫក្សពារល្អ ហើយអាចធ្វើការអ្វីមួយឲ្យជាទីសព្វព្រះទ័យនៃព្រះជាម្ចាស់បានទាំងអស់ ក្រៅពីធ្វើពិធីតាមទំនងនេះ ពួកលោកសង្ឃបានរៀបចំធ្វើប្រក្រតិទិនកំណត់ថ្ងៃល្អថ្ងៃអាក្រក់ដោយឡែកទៀតផង ។

ឯសាសនារបស់ពួកកេម៉ាំងនោះ មិនមានគោលការណ៍ល្មមហៅជាសាសនាទេ ព្រោះមិនមានពាក្យប្រដៅនិយាយពីវិញ្ញាណរបស់មនុស្ស ឬសីលធម៌ទេ កាលបើពួកកេម៉ាំងមិនមានលទ្ធិនិយាយពីសីលធម៌ មានតែជំនឿនឹងខ្មោច ហេតុនេះហើយបានជាមានព្រះច្រើនរាប់មិនអស់ ។

មួយវិញទៀត ពួកកេម៉ាំងនៅច្បាំងវាយឈ្នះបានស្រុកណាមកជាចំណុះ ក៏នាំយកទេវរូបដែលជាទីគោរពរបស់ស្រុកនោះ ចូលមកទុកក្រុងកេម ។ ការធ្វើដូច្នេះ ជាវិធីឲ្យកិត្តិយសដល់ព្រះរបស់ស្រុកដែលខ្លួនវាយបាននោះ ដើម្បីឲ្យប្រជាជនស្រុកនោះមានចិត្តជ្រះថ្លាស្រឡាញ់ជាតិកេម៉ាំង តែការដែលប្រមូលយកព្រះពីប្រទេសក្រៅចូលមកទុកច្រើនឡើងៗ ដូច្នេះ ជាហេតុឲ្យជំនឿនឹងសេចក្ដីកប់អានរបស់ជាតិកេម៉ាំងប្រែប្រួលទៅបាន ពោលគឺពួកកេម៉ាំងចំពួកខ្លះលើកលែងកប់អានព្រះរបស់ខ្លួនដែលធ្លាប់កប់អានមក បែរទៅគោរពកប់អានព្រះរបស់ក្រិកឬរបស់អេស៊ិប្ដ៍ ដែលពួកកេម៉ាំងនាំចូលមកក៏មាន ។

១ – អំពីទំនៀមប្រពៃណី — ការចិញ្ចឹមជីវិតរបស់ពួកកេម៉ាំងតាំងអំពីដើមរហូតមកដល់ពុទ្ធសករាជ ៥០០ មានទំនងដូចជាអ្នកនៅតាមជនបទខេត្រក្រៅ ពួកកេម៉ាំងចិញ្ចឹមជីវិតយ៉ាងងាយ ៗ ដូចមានរដ្ឋបុរសខ្លះបានធ្វើធំនៅក្រុងកេមដល់ទៅថ្នាក់ជាអ្នកសម្រេចការផែនដី ( ឌិកតាទ័រ ) នៅតែជីកដីដាំដំណាំដោយខ្លួនឯង ហើយមានអ្នកខ្លះធ្វើជាកុងស៊ុល (កុងស៊ុលរបស់ក្រុងកេមគ្រានោះ មានដំណែងប៉ុននឹងប្រធានាធិបតីក្នុងសម័យសព្វថ្ងៃនេះ) នៅតែប្រើពានឈើដាក់អាហារបរិភោគក៏មាន ។ តាមធម្មតា ពួកកេម៉ាំងជាអ្នកធ្វើការដាំណាំ ធ្វើជាទាហាននឹងធ្វើជារដ្ឋបុរស

តែមិនសូវមានធ្វើជាអ្នកជំនួញឬជាជាងចម្លាក់ទេ   បេតើប្រការខាងក្រោយនេះ  នៅក្នុងកណ្តាប់ដៃរបស់ជនជាតិតាងប្រទេសជាច្រើន ៗ

ពួកប្រុស ៗ ដែលជាធំក្នុងគ្រួសារនីមួយ ៗ រមែងមានអំណាចដាច់ស្រេចក្នុងគ្រួសាររបស់ខ្លួននឹងខ្ញុំកំដរទាំងពួងស្មើនឹងក្សត្រដែលទ្រង់ជាអាជ្ញាសិទ្ធិរាជ   គឺមានអំណាចនឹងសម្លាប់អ្នកណាមួយក្នុងគ្រួសារក៏បាន អំណាចទាំងនេះមាននៅក្នុងក្រុងរោមអស់កាលជាយូរអង្វែង ៗ  ឯពួកស្ត្រីជាតិរ៉ូម៉ាំង   មានលក្ខណៈសំខាន់ជាងស្ត្រីជាតិក្រិក   ដ្បិតនៅមានអំណាចទទួលដឹងព្តកិច្ចការផ្ទាល់ខ្លួនរបស់ស្វាមីខ្លួននៅខាងក្រៅផ្ទះបាន វេលាស្វាមីចូលទៅក្នុងការធ្វើពិធីបុណ្យផ្សេង ៗ  ភរិយាក៏អាចចូលទៅក្នុងបុណ្យនោះជាមួយនឹងស្វាមីរបស់ខ្លួនបាន វេលាស្វាមីចូលប្រជុំក្នុងរដ្ឋសភាភរិយានឹងចូលទៅអង្គុយស្តាប់ការប្រជុំជាមួយផងក៏បាន ៗ ហេតុនេះ បានជាក្នុងសម័យមួយនោះ  នៅក្រុងរោមចង់បញ្ញត្តច្បាប់ ១ ហាមមិនឲ្យស្ត្រីតែងខ្លួនហ៊ឺហាហួសពេកជាហេតុនាំឲ្យខាតបង់មាសប្រាក់ច្រើន ៗ  លុះដល់វេលាបោះឆ្នោតចេញច្បាប់នេះ    មិនមាននរណាហ៊ានបោះឆ្នោតព្រោះភរិយារបស់មន្ត្រីអស់នេះនាំគ្នាមកចោមរោមចាំមើលនៅជុំវិញរដ្ឋសភា ៗ  (មាឧត)

# រឿងចោរលួចក្រដាស

មាននិទានមួយដំណាលថា មានបុរសប្ដីប្រពន្ធអាស្រ័យនៅក្នុងភូមិមួយ បុរសជាប្ដីតែងទឹងទៅសិតក្រដាសសព្វៗថ្ងៃ ឯប្រពន្ធនៅផ្ទះក៏ប្រព្រឹត្តបទស្មន់អន្ទាក ។ មានកាលយប់ ១ អាសហាយមេនោះមកតែពុំទាន់បានឡើងទៅលើផ្ទះនៅឡើយផុនជាប្ដីមេនោះត្រឡប់មកពីសិតក្រដាសវិញក្នុងវេលាខុសប្រក្រតី ទុកក្រដាសលើគ្រែក្រោមផ្ទះយកដុំថ្មសង្កត់ស្រួលបួលហើយក៏ឡើងទៅលើផ្ទះ ។ ប្រពន្ធឃើញហើយភ្ញាក់ខ្លួនព្រើតសួរប្ដីថា ចុះបើទៅណាបាត់ពុំដែលនៅផ្ទះដល់មួយថ្ងៃសោះ ថ្ងៃណេះទើបឡើងមក ។ ប្ដីថា មេអើយ អញសង្ឃាតទៅសិតក្រដាសដើម្បីលក់យកប្រាក់ចិញ្ចឹមជីវិត ។ ប្រពន្ធថា ឥឡូវនេះក្រដាសទៅទុកឯណា ។ ប្ដីថា អញទុកលើគ្រែក្រោមផ្ទះយកថ្មសង្កត់លើក្រដាសនោះផង ។ ឯអាសហាយនៅក្រោមផ្ទះឮដូច្នោះក៏មានចិត្តត្រេកអរគិតថា ក្រដាសទាំងនេះមុខជាបានមកដៃអញមិនខានឡើយ ហើយក៏លួចយកក្រដាសនោះទាំងអស់ ។ លុះព្រឹកឡើងបុរសប្ដីនោះនាំប្រពន្ធទៅយកក្រដាសតែពុំឃើញដល់មួយពុម្ពឡើយ ។ ឯប្រពន្ធក៏ជេរប្ដី ទើបបុរសនោះយកខ្សែចងថ្មនោះហើយអូសទៅប្ដឹងចៅក្រមថា ខ្ញុំទុកក្រដាសហើយយកថ្មនេះសង្កត់ ឥឡូវនេះក្រដាសខ្ញុំបាត់ ខ្ញុំថាថ្មនេះឯងលួចក្រដាសខ្ញុំ

សូមឲ្យលោកពិចារណាសេចក្ដីនេះឲ្យបានហោង ៗ ឯចៅក្រមថា ចៅនេះឆ្កួតឬជា ក៏ជាចោរលួចក្រដាសដូច្នេះ ហើយចៅក្រមពុំដំនុំពិចារណាឲ្យឡើយ ៗ ឯបុរសម្ចាស់ក្រដាសនោះកើតទុក្ខពុំសុខចិត្ត ក៏នាំសេចក្ដីឡើងក្រាបបង្គំទូលសម្ដេចព្រះមហាក្សត្រាធិរាជដោយនូវដំណើរនោះ ៗ ព្រះអង្គត្រាស់ដណ្ដឹងថា ព្រះស្តែងមានប្រពន្ធឬឥតប្រពន្ធ ៗ បុរសនោះក្រាបបង្គំទូលថា ទូលព្រះបង្គំជាខ្ញុំមានប្រពន្ធ ៗ ទើបព្រះអង្គមានព្រះបន្ទូលថា បើដូច្នោះចូរចៅថយទៅសិន ចាំអញពិចារណាសេចក្ដីនោះមើល ៗ បុរសនោះក៏ក្រាបថ្វាយបង្គំលាវិលទៅកាន់លំនៅខ្លួនវិញ ៗ ទើបសម្ដេចព្រះមហាក្សត្រាធិរាជព្រះអង្គឲ្យយកគង់ទៅប៉ាវប្រាប់អស់មុខមន្ត្រីសេនាបតីធំតូចនូវរាស្ត្រផង ឲ្យបានដឹងថាព្រះអង្គមានការកម្រណាស់ ជាបើនរណាមានក្រដាសឲ្យយកទៅថ្វាយព្រះអង្គ ៗ នឹងចិញ្ចឹមអ្នកនោះ ៗ ឯអាចោរលួចក្រដាសនោះកាលបើបានឮអាជ្ញាប៉ាវគង់ដូច្នោះហើយក៏ម្នាយកក្រដាសដែលលួចគេនោះឡើងថ្វាយ ព្រះមហាក្សត្រក៏ត្រាស់ឲ្យហៅចៅម្ចាស់ក្រដាសមកមើល ក៏ស្គាល់ជាក់ជាក្រដាសរបស់ខ្លួនមែន ហើយព្រះអង្គត្រាស់ដណ្ដឹងទៅអាដែលលួចនោះថា ក្រដាសនេះតើព្រះស្តែងបានអំពីឯណា ៗ ឯអាចោរក្រាបទូលថា ខ្ញុំព្រះអង្គធ្វើឯង ៗ

ទើបព្រះអង្គត្រាស់ឲ្យធ្វើក្រដាសលមើល ។ អាចោរយល់ថាធ្វើពុំកើត ក៏ក្រាបទូលថា ទូលព្រះបង្គំជាខ្ញុំបានពីប្រពន្ធ ។ ព្រះអង្គត្រាស់ឲ្យទៅហៅប្រពន្ធ ឯអាចោរក្រាបទូលថា ទូលព្រះបង្គំជាខ្ញុំនឹងទៅយកមេនោះពុំបាន ដ្បិតទូលព្រះបង្គំជាខ្ញុំលួចគេទេ ទើបព្រះអង្គត្រាស់ដណ្ដឹងថា ព្រះស្ដែងលួចតែក្រដាសឬលួចទាំងប្រពន្ធគេផង ។ ឯអាចោរនោះនឹងលាក់ពុំបានក៏ក្រាបទូលថា ខ្ញុំព្រះអង្គលួចប្រពន្ធគេផង ។ ទើបសម្ដេចព្រះមហាក្សត្រាធិរាជព្រះអង្គឲ្យលក់អាប្រុសទូវមេស្រីនោះដាច់សរិលហោង ។ សេចក្ដីនេះជាអាថ៌កំបាំងឥតចៅក្រមឯណាពិចារណាបានឡើយ មានតែព្រះប្រាជ្ញាសម្ដេចព្រះមហាក្សត្រាធិរាជទើបឈ្វេងយល់សព្វគ្រប់ប្រការទាំងអម្បាលណោះហោង ។